ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំខែសីហា ឆ្នាំ២០២០ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងខែសីហា ឆ្នាំ២០២០នេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាធ្វើការដាំដុះបានចំនួន ២ ៥៤៧ ៤២០ហ.ត ស្មើនឹង៩៨,៤៣% នៃផែនការចំនួន ២ ៥៨៨ ១៣០ហ.ត។ រីឯការចូលរួមទប់ស្កាត់បទល្មើសផ្សេងៗទៀតជាពិសេស បទល្មើសព្រៃឈើ បទល្មើសជលផលក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង ព្រមទាំងបទល្មើសចលនាសត្វដោយខុសច្បាប់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងខែសីហា ឆ្នាំ២០២០នេះ គឺបានរៀបចំកិច្ចប្រជុំសំខាន់ៗ រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។ ចំពោះលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំ២០២០ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានក្នុងខែសីហា ឆ្នាំ២០២០នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ លទ្ធផលផ្នែកដាំដុះ

#### ១.១ ផលិតកម្មដំណាំស្រូវរដូវវស្សា

ល្បឿនការងារបង្កបង្កើនផលដំណាំស្រូវរដូវវស្សាគិតត្រឹមថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០ មានលម្អិតដូចខាងក្រោម៖

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ២ ៦២៦ ២៥៩ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ២៤ ១៤១ហ.ត និងដោយគ្រឿងយន្តមានចំនួន ២ ៦០២ ១១៨ហ.ត តិចជាងឆ្នាំមុនចំនួន ២៧ ៦៦៦ហ.ត
- ផ្ទៃដីសាបសម្រេចបានចំនួន ១៤ ៥៦៣ហ.ត តិចជាងឆ្នាំមុនចំនួន ៨ ០០៣ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ២ ៥៤៧ ៤២០ហ.ត ស្មើនឹង៩៨,៤៣% នៃផែនការចំនួន ២ ៥៨៨ ១៣០ហ.ត លើសឆ្នាំមុនចំនួន ៧១ ១៩៩ហ.ត។

#### ១.២ ការប្រមូលផលស្រូវស្រាលដើមរដូវវស្សា

ការប្រមូលផលស្រូវស្រាលសម្រេចបានចំនួន ១៨១ ៦២៤ហ.ត ដោយទទួលបរិមាណផលសរុបចំនួន ៧៤០ ៣០៧តោន លើសឆ្នាំមុនចំនួន ៥៥ ៣៣៩តោន និងទទួលបានទិន្នផលគិតជាមធ្យម ៤,០៧៦តោន/ហ.ត។

#### ១.៣ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្មរដូវវស្សា

-ដំណាំសាកវប្បកម្មអនុវត្តបានសរុបចំនួន ៥២ ៤២៩ហ.ត ស្មើនឹង១០៦,០៨% នៃផែនការចំនួន ៤៩ ៤២៤ហ.ត លើសឆ្នាំមុនចំនួន ៥ ៧៧០ហ.ត

-ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៧៦៣ ៨១១ហ.ត ស្មើនឹង៨៧,៣៣% នៃផែនការចំនួន ៨៧៤ ៥៩៥ហ.ត តិចជាងឆ្នាំមុនចំនួន ៤១៤ហ.ត។

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣ ២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

### ១.៤ ស្ថានភាពប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ

ដំណាំស្រូវនៅខេត្តចំនួន ១០កំពុងរងផលប៉ះពាល់ និងខូចខាតដោយគ្រោះរាំងស្ងួត ដោយទទួលរងផលប៉ះពាល់សរុបចំនួន ១៣៤ ៥៣២ហ.ត ស្មើនឹង៩,៨៤%។ តាមការវាយតម្លៃ ដំណាំស្រូវបានខូចខាតសរុបចំនួន ៧ ៦៨៥ហ.ត ស្មើនឹង៥,៧១% នៃផ្ទៃដីផលប៉ះពាល់សរុប។

### ១.៥ ការនាំចេញផលិតផលកសិកម្ម

**១.៥.១ ការនាំចេញអង្ករ**

បរិមាណនាំចេញអង្ករបានចំនួន ២២ ១៣០តោន មានការថយចុះចំនួន ១១ ៩០២តោន (-៣៤,៩៧%) តិចជាងបរិមាណនាំចេញក្នុងខែសីហា ឆ្នាំ២០១៩ មានចំនួន ៣៤ ០៣២តោន។ សរុបរយៈពេល៨ខែនាំចេញអង្ករបានចំនួន ៤៤៨ ២០៣តោន និងនាំចេញទៅកាន់ទិសដៅចំនួន ៥៩ប្រទេស ក្នុងនោះប្រទេសចិនលំដាប់ទី១ចំនួន ១៥៩ ២៥៣តោន ប្រទេសបារាំងលំដាប់ទី២ចំនួន ៥៦ ៩៦៤តោន ប្រទេសហ្គាបុងលំដាប់ទី៣ចំនួន ៣៤ ៤៦៦តោន ប្រទេសម៉ាឡេស៊ីលំដាប់ទី៤ចំនួន ២៣ ២០១តោន ប្រទេសអូស្ត្រាលីលំដាប់ទី៥ចំនួន ២០ ៩១៥តោន ប្រទេសណេដឺឡែនលំដាប់ទី៦ចំនួន ១៨ ៥៣៤តោន ប្រទេសវៀតណាមលំដាប់ទី៧ចំនួន ១២ ៨៣៦តោន ប្រទេសអង់គ្លេសលំដាប់ទី៨ចំនួន ១១ ៣៥៦តោន ប្រទេសប្រ៊ុយណេលំដាប់ទី៩ចំនួន ១០ ៥០០តោន និងប្រទេសអេស្ប៉ាញលំដាប់ទី១០ចំនួន ១០ ១១១តោន ហើយបច្ចុប្បន្នក្រុមហ៊ុនបាននាំចេញអង្ករមានចំនួន ៧១ក្រុមហ៊ុន។

**១.៥.២ ការនាំចេញផ្លែឈើ**

បរិមាណនាំចេញផ្លែចេកស្រស់បានចំនួន ២៨ ៩២៦,៦៥តោន ទៅកាន់ប្រទេសចិន វៀតណាម និងប្រទេសជប៉ុន។ ផ្លែស្វាយ ៤៧០តោន ទៅកាន់ប្រទេសថៃ។ គ្រាប់ពោត ៧០ ២១០,២០តោន ទៅកាន់ប្រទេសថៃ និងតៃវ៉ាន់។

## ២ ផ្នែកផលិតកម្មកៅស៊ូ

**២.១ ផ្ទៃដីកៅស៊ូ**

- ផ្ទៃដីកៅស៊ូសរុបចំនួន ៤០៤ ៧០១ហ.ត ក្នុងនោះ ផ្ទៃដីចៀរជ័រចំនួន ២៥០ ១០៧ហ.ត ស្មើនឹង៦២% និងផ្ទៃដីថែទាំចំនួន ១៥៤ ៥៩៤ហ.ត ស្មើនឹង៣៨%។

**២.២ ផលិតកម្មកៅស៊ូ**

- ផលិតផលជ័រកៅស៊ូសម្រេចបានចំនួន ២៨ ១៦៣តោន កើនឡើងចំនួន ២ ៤៦០តោន ស្មើនឹង១០% ធៀបខែមុន និងកើនឡើងចំនួន ៥ ៣០៥តោន ស្មើនឹង២៣% ធៀបខែសីហា ឆ្នាំ២០១៩។

**២.៣ ការនាំចេញកៅស៊ូ**

- បរិមាណបញ្ចេញលក់សម្រេចបានចំនួន ២៥ ៩៥៣តោន កើនឡើងចំនួន ៥២៧តោន ស្មើនឹង២% ធៀបខែមុន និងកើនឡើងចំនួន ៤ ៣៧០តោន ស្មើនឹង២០% ធៀបខែសីហា ឆ្នាំ២០១៩។

**២.៤ តម្លៃកៅស៊ូ**

- តម្លៃលក់មធ្យមក្នុងខែសីហា គឺ១ ២៧៥ដុល្លារ/តោន កើនឡើងចំនួន ៨៤ដុល្លារ/តោន ស្មើនឹង៧,០២% ធៀបខែមុន និងថយចុះចំនួន ១២១ដុល្លារ/តោន ស្មើនឹង៨,៦៨% ធៀបខែសីហា ឆ្នាំ២០១៩
- តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារចម្ការក្នុងខែសីហា គឺទឹកជ័រ (DRC 100%) មានការប្រែប្រួលពី ៤ ០៥០៛/គ.ក្រ ដល់ ៤ ៥០០៛/គ.ក្រ និងជ័រកក (DRC50%) មានការប្រែប្រួលពី ១ ៨៥០៛/គ.ក្រ ដល់ ២ ២៧៥៛/គ.ក្រ។

## ៣ ផ្នែកព្រៃឈើ

### ៣.១ ការងារព្រៃឈើ

- បានទាញយករូបភាពផ្កាយរណប (Sentinel2) ឆ្នាំ២០២០ ចំនួន ៥ផ្ទាំងសម្រាប់បន្តការវាយតម្លៃគម្របព្រៃឈើឆ្នាំ២០២០ និងកំពុងវាយតម្លៃ និងផ្ទៀងផ្ទាត់គម្របព្រៃឈើលើរូបភាពផ្កាយរណប
- បានយល់ព្រមជាគោលការណ៍លើផែនការគ្រប់គ្រងព្រៃសហគមន៍ព្រៃឈើសាមគ្គីព្រែកជី ខេត្តកោះកុង និងសហគមន៍ព្រៃឈើជម្រកសត្វខេត្តស្ទឹងត្រែងមានផ្ទៃដីសរុបទំហំ ៤ ៤៧៦ហ.ត
- បានផ្ដល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្ត និងយានយន្តជូនក្រុមហ៊ុន ហ្វ្រីនស៊ី អេហ្វ្រីខលឈ័រ ខេត្តស្ទឹងត្រែងមានរណារយន្តចំនួន ២១គ្រឿង និងយានយន្តចំនួន ១៧គ្រឿង
- បានផ្ដល់លិខិតបើកផ្លូវដឹកជញ្ជូនផលអនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន ២ក្រុមហ៊ុន និងអ្នកស្នើសុំចំនួន ១នាក់ មានឈើហ៊ុបមូលចំនួន ២ ០៦៩ម៣ កូនឈើចំនួន ៩ ០០៤ដើម អុសចំនួន ៣ ៣៧៥ស្ទេរ និងជ័រទឹកចំនួន ១០០តោន។

### ៣.២ ការងារអភិរក្សសត្វព្រៃ

- បានសហការជាមួយវិទ្យាស្ថានប៉ាស្ទ័រកម្ពុជាដើម្បីចុះដាក់អង្គប់ និងប្រមូលសំណាកសត្វកណ្ដុរនៅស្រុកព្រៃឈរ និងស្រុកកំពង់សៀម ខេត្តកំពង់ចាម ដោយប្រមូលសំណាកសត្វកណ្ដុរបានចំនួន ៨៥ក្បាល

- បានសហការជាមួយអង្គការ FFI ដើម្បីចុះពិនិត្យម៉ាស៊ីនថតស្វ័យប្រវត្តិចំនួន ៩គ្រឿងដែលបំពាក់សម្រាប់តាមដានវត្តមាន និងកត្តាគំរាមកំហែងចំពោះសត្វព្រៃ និងដំរីព្រៃនៅតំបន់ជួរភ្នំក្រវាញក្នុងខេត្តកោះកុង និងខេត្តព្រះសីហនុ

- បានចេញលិខិតអនុញ្ញាតដឹកជញ្ជូនសត្វព្រៃជូនក្រុមហ៊ុនចំនួន ៥ច្បាប់មានស្វាក្ដាមចំនួន ៣ ៤០០ក្បាល ក្នុងនោះដឹកជញ្ជូនក្នុងស្រុកចំនួន ១ ៦០០ក្បាល និងនាំចេញទៅក្រៅប្រទេសចំនួន ១ ៨០០ក្បាល

- បានចេញលិខិតអនុញ្ញាតថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារចំនួន ៤ច្បាប់ ក្នុងនោះ ១ច្បាប់សម្រាប់ ការថែរក្សាសត្វត្រចៀកកាំ និង ៣ច្បាប់សម្រាប់ការថែរក្សាសត្វព្រៃប្រភេទផ្សេងទៀតមានទីតាំងនៅរាជធានីភ្នំពេញ និងខេត្តកណ្ដាល។

### ៣.៣ កសិដ្ឋានចិញ្ចឹម បង្កាត់ពូជស្វាក្ដាម និងការសង្គ្រោះសត្វព្រៃ

- ក្រុមហ៊ុនចំនួន ៧មានកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្ដាមយកកូននាំចេញចំនួន ៨កន្លែង ស្ថិតនៅរាជធានីភ្នំពេញ ខេត្តកំពង់ធំ សៀមរាប កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំងមានសត្វស្វាក្ដាមសរុបចំនួន ៦៧ ៣៥២ក្បាល

- នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅមានសត្វព្រៃសរុបចំនួន ១ ៦១៧ក្បាល (បក្សីចំនួន ៥៦ប្រភេទ ថនិកសត្វចំនួន ៤៦ប្រភេទ និងល្មូនចំនួន ១៦ប្រភេទ) សង្គ្រោះសត្វថ្មីចំនួន ១២៨ក្បាល ព្យាបាលសត្វព្រៃរបួសឈឺចំនួន ៣៤ក្បាល ស្ដារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងដោះលែងទៅព្រៃធម្មជាតិវិញនូវសត្វព្រៃគ្រប់ប្រភេទចំនួន ៣៩ក្បាល

- គម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការ FFI បានល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន ៥ គឺ អារ៉ែង ឆាយរាប តំបន់ស្ដារក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)

- បានជួសជុលផ្លូវក្រាលក្រួសក្រហមសរុបប្រវែង ៨ ២០០ម៉ែត្រការ៉េ និងកាប់ឆ្ការអនាម័យព្រៃទំហំ ១,១៥ហ.ត នៅក្នុងតំបន់សួនសត្វ។

### ៣.៤ ការងារដាំដើមឈើ

- បាននិងកំពុងថែទាំប្រឡាយប្រវែង ១៨ ០០០ម៉ែត្រ ក្នុងនោះប្រឡាយជីកឆ្នាំ២០១៨ ប្រវែង ១០ ០០០ម៉ែត្រ និងឆ្នាំ២០១៩ មានប្រវែង ៨ ០០០ម៉ែត្រនៅក្នុងខេត្តកំពង់ធំ និងខេត្តព្រះសីហនុ

- បាននិងកំពុងថែទាំចម្ការឈើសរុប ៩៣២ហ.ត ក្នុងនោះចម្ការពូជឈើ ៨៩ហ.ត ឡូត៍បង្ហាញកសិ-រុក្ខកម្ម ៤៩ហ.ត ចម្ការឈើដាំទំហំ ៧៥៤ហ.ត និងចម្ការរុក្ខទិវា ៩ សីហា ទំហំ ៤០ហ.ត នៅក្នុងខេត្តកំពត កណ្ដាល សៀមរាប ព្រះសីហនុ ស្វាយរៀង កំពង់ធំ និងខេត្តក្រចេះ

- បានបណ្ដុះកូនឈើចំនួន ១៤ ៥៤៥ដើម ក្នុងនោះថ្នាលបណ្ដុះកូនឈើតាមបណ្ដាខណ្ឌរដ្ឋបាលព្រៃឈើនៅទូទាំងប្រទេសចំនួន ១៤ ៥៤៥ដើម និងបានប្រគេនកូនឈើដល់ព្រះសង្ឃ និងចែកជូនប្រជាពលរដ្ឋចំនួន ៧១ ៥៨១ដើម ក្នុងនោះថ្នាលបណ្ដុះកូនឈើខណ្ឌរដ្ឋបាលបាលព្រៃឈើនៅទូទាំងប្រទេសចំនួន ៥៨ ៩៩១ដើម និងថ្នាលបណ្ដុះកូនឈើចំនួន ៦កន្លែង ក្នុងខេត្តចំនួន ៥រួមមានខេត្តពោធិ៍សាត់ កំពង់ធំ តាកែវ កំពង់ចាម និងខេត្តកណ្ដាល២កន្លែងសរុបចំនួន ១២ ៥៩០ដើម។

### ៣.៥ ការងារនីតិកម្មនិងវិវាទ

- សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃសរុបចំនួន ១១៩ករណី ដោយពិន័យអន្តរការណ៍ចំនួន ៤៣ករណី និងបញ្ជូនទៅតុលាការចំនួន ៧៦ករណី

- ចំពោះវត្ថុតាងនៃបទល្មើសព្រៃឈើដែលបានចាប់យាត់ និងដកហូតរួមមានឈើមូល-ជ្រុងសរុបចំនួន ៣៩ម៣ ឈើអារចំនួន ៣១០ម៣ ផ្ទៃដីព្រៃឈើដែលបានកាប់រានទំហំ ៤០៦ហ.ត វត្ថុតាងសត្វព្រៃដែលបានចាប់យាត់មានចំនួន ៨៥ក្បាល និង១០,៥០គ.ក្រ និងអនុផលព្រៃឈើ ព្រមទាំងសម្ភារផ្សេងៗមួយចំនួនទៀត។

### ៣.៦ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- បានចុះពិនិត្យសិក្សាបង្កើតរោងម៉ាស៊ីនអារកែច្នៃផលអនុផលព្រៃឈើចំនួន ២កន្លែង

- បានពន្យារសុពលភាពរោងម៉ាស៊ីនកែច្នៃឈើ និងផលិតគ្រឿងសង្ហារិមចំនួន ៥កន្លែង របស់ក្រុមហ៊ុន ធី.អេស.អិម.ដាប់បែលយូ និងលោកស្រី យូ ស្រយ

- ក្រុមហ៊ុនចំនួន ៤បាននាំចេញផលិតផលរានទេវតា ឈើកែច្នៃ និងជ័រទឹកទៅក្រៅប្រទេសចំនួន ៣០៣ម៣ និងជ័រទឹកចំនួន ២៩តោន

- ក្រុមហ៊ុនចំនួន ២បាននាំចូលឈើកែច្នៃមានបរិមាណចំនួន ២០៤ម៣

- បានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន ២ក្រុមហ៊ុន មានឈើកែច្នៃចំនួន ១១៥ម៣ និងឬស្សីកែច្នៃចំនួន ៧តោន។

### ៣.៧ ការងារចំណូលព្រៃឈើ

- បានចំណូលពីថ្លៃសួយសារផលអនុផលព្រៃឈើចំនួន ១ ៩៣៧ ៥៩៩ ៦១៣រៀល និង ៤១៧ ៤៧១,៩៨ ដុល្លារ។

## ៤ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

**៤.១ ការងារផលិតកម្មសត្វ៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តារាជធានី-ខេត្តរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើស្ទូនដំណាំចំណីសត្វ ការផ្តល់ពូជស្មៅដល់កសិករ និងភ្នាក់ងារសុខភាពសត្វភូមិ និងចុះពិនិត្យនិងកែសម្រួលឡជីវឧស្ម័នដែលបានសាងសង់រួចហើយ ដែលមានបញ្ហាបច្ចេកទេសនៅតាមខេត្តគោលដៅ។

### ៤.២ ការងារសុខភាពសត្វ

- **លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖** បទល្មើសសត្វនិងផលិត-ផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យ និងបង្ក្រាបយ៉ាងសកម្មដោយក្រុមអន្តរាគមន៍របស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន ៣១ករណី ក្នុងនោះមិនមានលិខិតអនុញ្ញាតត្រឹមត្រូវ១ករណី និងមានលិខិតអនុញ្ញាតត្រឹមត្រូវ៣០ករណី។ រាជធានី-ខេត្តចំនួន ២១ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ៥ ៦៧៣លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្ត-ឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។
- **ការងារផ្សព្វផ្សាយបច្ចេកទេស៖** ចុះបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ និងបច្ចេកទេសដាំដំណាំចំណីសត្វនៅតាមបណ្តាខេត្តចំនួន ៦ខេត្ត ដោយមានអ្នកចូលរួមសរុប ១៦១នាក់។
- **ការងារនីតិកម្ម និងវិវាទ** បាននិងកំពុងរៀបចំលិខិតបទដ្ឋានគតិយុត្តមួយចំនួនទៀត។

### ៤.៣ ការងារស្រាវជ្រាវ

- **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១០៩ក្បាល។
- **ការងារស្រាវជ្រាវសុខភាពសត្វ៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺ និងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបបានចំនួន ១ ៩៧៤វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី និងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF)។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

- ដាយត្រីបានបញ្ចប់ត្រឹមចំនួន ១ ៥០០តោន ស្មើនឹង១២,៥០% នៃផែនការចំនួន ១២ ០០០តោន ប្រៀបធៀបខែសីហា ឆ្នាំ២០១៩ ថយចុះចំនួន ៨៧០តោន

- នេសាទគ្រួសារក្នុងដែននេសាទអនុវត្តបានចំនួន ១៨ ១០០តោន សរុបរយៈពេល៨ខែចំនួន ១៧០ ៤០០តោន ស្មើនឹង ៤៩,៣៩%នៃផែនការចំនួន ៣៤៥ ០០០តោន ប្រៀបធៀបខែសីហា ឆ្នាំ២០១៩ ថយចុះចំនួន ១ ៧០០តោន

- នេសាទគ្រួសារតាមវាលស្រែអនុវត្តបានចំនួន ១០ ៩៨០តោន សរុបរយៈពេល៨ខែចំនួន ៥១ ១៦៦តោន ស្មើនឹង ៣៥,២៩%នៃផែនការចំនួន ១៤៥ ០០០តោន ប្រៀបធៀបខែសីហា ឆ្នាំ២០១៩ ថយចុះចំនួន ១ ០៦៤តោន។

#### ៥.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ៩ ៧០០តោន សរុបរយៈពេល៨ខែចំនួន ៧៧ ៤១០តោន ស្មើនឹង៧០,៣៧% នៃផែនការចំនួន ១១០ ០០០តោន ប្រៀបធៀបខែសីហា ឆ្នាំ២០១៩ ថយចុះចំនួន ១៩០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គាអនុវត្តបានចំនួន ៥៥ ១៦៤តោន សរុបរយៈពេល៨ខែចំនួន ២៣៩ ៦៥៤តោន ស្មើនឹង ៦៦,៥៧% នៃផែនការចំនួន ៣៦០ ០០០តោន ប្រៀបធៀបខែសីហា ឆ្នាំ២០១៩ កើនឡើងចំនួន ៤០ ៦៩៦តោន
- ការចិញ្ចឹមក្រពើអនុវត្តបានចំនួន ៤០ ០៥០ក្បាល សរុបរយៈពេល៨ខែចំនួន ២២១ ២៩០ក្បាល ស្មើនឹង៧៣,៧៦% នៃផែនការចំនួន ៣០០ ០០០ក្បាល ប្រៀបធៀបខែសីហា ឆ្នាំ២០១៩ កើនឡើងចំនួន ២៩០ក្បាល
- ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន ២០ ៣០០ ០០០កូន សរុបរយៈពេល៨ខែចំនួន ១៤១ ៨០០ ០០០កូន ស្មើនឹង ៥៩,០៨% នៃផែនការចំនួន ២៤០ ០០០ ០០០កូន ប្រៀបធៀបខែសីហា ឆ្នាំ២០១៩ កើនឡើងចំនួនប្រមាណ ៨០០ ០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទអនុវត្តចំនួន ៧ ៣០០តោន សរុបរយៈពេល៨ខែចំនួន ៤០ ៣៥០តោន ស្មើនឹង៤៩,២១% នៃផែនការចំនួន ៨២ ០០០តោន ប្រៀបធៀបខែសីហា ឆ្នាំ២០១៩ ថយចុះចំនួន ១ ៧០០តោន
- ផលនេសាទសមុទ្រអនុវត្តបានចំនួន ៨១០តោន សរុបរយៈពេល៨ខែចំនួន ៧ ៧៥០តោន ស្មើនឹង៨៦,១១% នៃផែនការចំនួន ៩ ០០០តោន ប្រៀបធៀបខែសីហា ឆ្នាំ២០១៩ កើនឡើងចំនួន ១០តោន
- ការផលិតទឹកត្រីអនុវត្តបានចំនួន ២ ០០០ ០០០លីត្រ សរុបរយៈពេល៨ខែចំនួន ៤០ ៥១២ ០០០លីត្រ ស្មើនឹង៧៣,៦៦% នៃផែនការចំនួន ៥៥ ០០០ ០០០លីត្រ ប្រៀបធៀបខែសីហា ឆ្នាំ២០១៩ ថយចុះចំនួន ២ ៣០៨ ០០០លីត្រ។

### ៥.៤ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផល

- សំណុំរឿងបទល្មើសជលផលមានចំនួន ២៩២ករណី ប្រៀបធៀបខែសីហា ឆ្នាំ២០១៩ ថយចុះចំនួន ១៦៦ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ២៦០ករណី និងសមុទ្រចំនួន ៣២ករណី។

### ៥.៥ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់នាំចេញក្នុងខែពុំមាន សរុបរយៈពេល៨ខែចំនួន ១ ១៤០តោន ស្មើនឹង៧,៦០% នៃផែនការចំនួន ១៥ ០០០តោន ប្រៀបធៀបខែសីហា ឆ្នាំ២០១៩ ថយចុះចំនួន ៥ ៣៧០តោន
- ផលនេសាទកែច្នៃនាំចេញក្នុងខែពុំមាន សរុបរយៈពេល៨ខែចំនួន ២៣២តោន ស្មើនឹង៤,៦៤% នៃផែនការចំនួន ៥ ០០០តោន ប្រៀបធៀបខែសីហា ឆ្នាំ២០១៩ ថយចុះចំនួន ៣ ៣៨៨តោន។

### ៥.៦ ការប្រមូលថវិកា

- ចំណូលពីសេវាផ្សេងៗក្នុងផ្នែកជលផលក្នុងខែពុំមាន សរុបរយៈពេល៨ខែចំនួន ៤៥៥ ៣៩៨ ៣៦០រៀល ស្មើនឹង ១៥,២១% នៃផែនការចំនួន ២ ៩៩៤ ០០០ ០០០រៀល ប្រៀបធៀបខែសីហាឆ្នាំ២០១៩ ថយចុះចំនួន ៦៦ ៥៣៥ ៤៨៨រៀល។

## ៦ ផ្នែកអគ្គាធិការដ្ឋាន

- បានចុះត្រួតពិនិត្យលើការងារដឹកនាំ គ្រប់គ្រងរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រះវិហារ សៀមរាប ស្ទឹងត្រែង និងខេត្តក្រចេះ និងជំរុញការកែលម្អចំណុចខ្វះខាតដែលក្រសួងចេញលិខិតឱ្យកែលម្អកន្លងមក
- បានចុះត្រួតពិនិត្យទីតាំងដីស្ថានីយបណ្តុះកូនឈើហូបផ្លែរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តប៉ៃលិន
- ប្រព័ន្ធអ៊ិនធើណេតរបស់អគ្គាធិការដ្ឋានសម្រាប់ការទទួលពាក្យបណ្តឹងបានរៀបចំរួចរាល់អាចដំណើរការបាន តាមគេហទំព័រឈ្មោះ www.gi.maff.gov.kh
- បានស្រាវជ្រាវព័ត៌មានតាមបណ្តាគេហទំព័រពាក់ព័ន្ធនឹងវិស័យកសិកម្មចំនួន ១០៥ករណី
- បានចូលរួមកម្មវិធីប្រជុំ សិក្ខាសាលា និងការងារសង្គមចំនួន ៩លើក។

## ៧ ផ្នែករដ្ឋបាល

- បានទទួលលិខិតសរុបចំនួន ៦២០ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ២៦៦ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ២១៩ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ១៣៥ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល
- បានបញ្ជូនឯកសារ និងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ១ ០៩៤ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ១៤ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ៣០ច្បាប់
- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ

- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំដើម្បីក្តាប់ឱ្យបានរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ ការរៀបចំកិច្ចប្រជុំនិងពិធីបុណ្យផ្សេងៗ ការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ៖ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម)។

## ៨ ផ្នែកបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន ៥ ៨៦៨នាក់ (ស្រី១ ៤២២នាក់) ស្មើនឹង២៤,២៣% រួមមាន៖
  - \+ អង្គភាពថ្នាក់កណ្តាលចំនួន ចំនួន២ ៩២៥នាក់ (ស្រី៨២៥នាក់) ស្មើនឹង២៨,២០%
  - \+ អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ២ ៩៤៣នាក់ (ស្រី៥៩៧នាក់) ស្មើនឹង២០,២៨%
- បានរៀបចំប្រកាសលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌដោយមរណភាពមានចំនួន ២នាក់
- បានរៀបចំប្រកាសស្តីពីការទទួលស្គាល់មន្ត្រីរាជការផ្ទេរមកពីក្រៅក្រសួងចំនួន ១នាក់
- បានរៀបចំលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកការងារមានចំនួន ១០នាក់ (ស្រី៦នាក់) ក្នុងនោះ ច្បាប់ឈប់សម្រាកព្យាបាលជំងឺ២នាក់ និងច្បាប់ឈប់សម្រាកលំហែមាតុភាព៣នាក់ និងច្បាប់សម្រាកប្រចាំឆ្នាំ៥នាក់
- បានរៀបចំប្រកាសដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សចំនួន ៦នាក់ (ស្រី៣នាក់)
- ការងារបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសសរុបចំនួន ២១០នាក់ (ស្រី៣៤នាក់) ក្នុងនោះ៖
  - \+ ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លី និងមធ្យមសរុបចំនួន ២០៤នាក់ (ស្រី៣១នាក់)
  - \+ ការបណ្តុះបណ្តាលក្រៅប្រទេសសរុបចំនួន ៦នាក់ (ស្រី៣នាក់)។

## ៩ ផ្នែកផែនការ និងស្ថិតិ

- បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់សម្រាប់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មរាជធានី-ខេត្ត ឆ្នាំ២០១៩-២០២៣ នៅខេត្តកំពង់ធំ និងខេត្តសៀមរាប
- បានចុះប្រមូលឯកសារពាក់ព័ន្ធនឹងការចុះបញ្ជីដីជាដីឯកជនរបស់រដ្ឋក្នុងគោលដៅសម្បទានដីសេដ្ឋកិច្ចរបស់គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចនៅក្នុងខេត្តកំពង់ធំ
- បានអនុញ្ញាតជាគោលការណ៍ឱ្យមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ឆ្នាំងបញ្ចេញស្រូវពូជចាស់អន់គុណភាពចំនួន ១០ ៦៣៣គ.ក្រ
- បានរៀបចំប្រមូលផ្តុំឯកសារវិនិយោគសម្បទានដីសេដ្ឋកិច្ចតាមបណ្តាក្រុមហ៊ុនដើម្បីថែរក្សាទុក
- បានធ្វើអង្កេតស្ទង់ទិន្នផលស្រូវស្រាលដើមរដូវឆ្នាំ២០២០ នៅខេត្តស្វាយរៀង និងខេត្តបន្ទាយមានជ័យ
- បានចុះស្រង់ទិន្នន័យតម្លៃទីផ្សារកសិផលទូទាំង២៥ រាជធានី-ខេត្ត
- បានចុះរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់បរិស្ថានដល់កសិករចំនួន ៣វគ្គ មានអ្នកចូលរួមចំនួន ៨៩នាក់ (ស្រី៤១នាក់) នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ។

## ១០ ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ

- បានអនុវត្តប្រមូលចំណូលនូវទឹកប្រាក់សរុបចំនួន ៨ ១៥០ ២៧១ ២៣០រៀល
- អង្គភាពប្រមូលចំណូលទាំង៦បានចុះប្រតិបត្តិការចំណូលក្នុងប្រព័ន្ធNRMIS ចំនួន ៧ ៣១៣ ១៦៥ ៧៤៩រៀល
- បានបញ្ចេញអាណត្តិបើកប្រាក់ពីក្រសួងសរុបមានចំនួន ២ ៣២៦ ៦៧៧ ០០០រៀល
- បានរៀបចំលិខិតសំណើសុំគោលការណ៍ធានាចំណាយតណាទានថវិកាជំពូក២១ ចំនួន ១៧ ២២៦ ៣៦៨ ០០០រៀល សម្រាប់វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពស្ថានីយបូមទឹកបណ្តែត អាងស្តុកទឹកបឋមផ្ទះសំណាញ់ (Net House) និងភ្ជាប់បណ្តាញអគ្គិសនីនៅតាមសហគន៍កសិកម្មឆ្នាំ២០២០
- បានរៀបចំលិខិតជូនដំណឹងស្តីពីកាតព្វកិច្ចបង់ថ្លៃសម្បទានដីសេដ្ឋកិច្ចជូនក្រុមហ៊ុនចំនួន ៥ក្រុមហ៊ុន
- បានចុះពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជីគណនេយ្យឆ្នាំ២០១៩ និងត្រួតពិនិត្យការផ្គូផ្គងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិឆ្នាំ២០១៩ របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ តាកែវ កំពត កែប ព្រៃវែង ស្វាយរៀង កំពង់ធំ និងខេត្តសៀមរាប

- បានធ្វើការប្រគល់ ទទួល និងបញ្ចប់សុពលភាពការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនៅស្ថានីយពិសោធន៍កសិកម្មរបស់អគ្គនាយកដ្ឋានកសិកម្មនៅខេត្តកំពង់ស្ពឺ និងខេត្តកណ្តាល។

**១១ ផ្នែកសវនកម្មផ្ទៃក្នុង**

- ធ្វើការផ្តល់ទិន្នន័យអំពីតម្រូវការបណ្តុះបណ្តាល និងវិក្រឹតការសម្ថភាពមន្ត្រីរាជការលើជំនាញគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់ឆ្នាំ២០២១

- ធ្វើការចាត់បញ្ជូនសវនករផ្ទៃក្នុងចំនួន ២នាក់ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលអនឡាញលើគោលការណ៍ណែនាំស្តីពីសវនកម្មសមិទ្ធកម្ម សវនកម្មលើគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងសវនកម្មបច្ចេកវិទ្យាព័ត៌មាន

- ធ្វើការចាត់បញ្ជូនមន្ត្រីជំនាញចំនួន ២នាក់ចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពីសមិទ្ធផលប្រព័ន្ធព័ត៌មានវិទ្យាក្នុងវិស័យកសិកម្ម

- បានចុះធ្វើសវនកម្មតាមផែនការសកម្មភាពសវនកម្មផ្ទៃក្នុងបានចំនួន ១សវនដ្ឋាន នៅមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម។

**១២ ផ្នែកសហប្រតិបត្តិការអន្តរជាតិ**

- បានចូលរួមទស្សនកិច្ចចំនួន ១លើកក្រោមក្របខ័ណ្ឌទ្វេភាគី និងពហុភាគី

- បានធ្វើលិខិតសម្របសម្រួល និងរៀបចំលិខិតដើម្បីចូលរួមកិច្ចប្រជុំ ព្រមទាំងឯកសារផ្សេងៗជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីក្រោមឱវាទ

- ក្រោយពីចុះហត្ថលេខលើអនុស្សរណៈយោគយល់គ្នាជាមួយក្រុមហ៊ុនវិទ្យាសាស្ត្រឧស្សាហកម្មធុនធ្ងន់ និងបច្ចេកវិទ្យា Zoomlion កាលថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ពេលនេះ ក្រុមហ៊ុនបានបញ្ជូនគ្រឿងយន្តកសិកម្មដែលគិតជាទឹកប្រាក់សរុបប្រមាណ ១៣ម៉ឺនដុល្លារ។

**១៣ ផ្នែកនីតិកម្មកសិកម្ម (ខែចាស់)**

**១៣.១ ការងារអាជីវកម្មជី-ថ្នាំកសិកម្ម**

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២០ក្រុមហ៊ុន សរុបចំនួន ១៨៦មុខ
- ផ្តល់លិខិតអនុញ្ញាតនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១៨ក្រុមហ៊ុន
- ចេញវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៥ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៣ក្រុមហ៊ុន។

**១៣.២ ការងារមន្ទីរពិសោធន៍**

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ៨ក្រុមហ៊ុន សរុបចំនួន ៤៧សំណាក។

**១៣.៣ ការងារអភិវឌ្ឍបទដ្ឋានគតិយុត្ត**

- បានប្រកាសអន្តរក្រសួងស្តីពីគោលការណ៍ណែនាំវិធានសុវត្ថិភាពក្នុងការប្រើប្រាស់ថ្នាំកសិកម្ម ការបោះសំណល់ពីការប្រើប្រាស់ថ្នាំកសិកម្ម និងសំបកវេចខ្ចប់ថ្នាំកសិកម្ម

- បានបើកវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈដល់អាជីវករ អ្នកលក់ដុំលក់រាយថ្នាំកសិកម្ម និងជីកសិកម្មនៅខេត្តកំពង់ធំមានអ្នកចូលរួមចំនួន ១៤០នាក់។

**១៣.៤ ការងារអនុវត្តច្បាប់**

- ប្រកាសប្រតិវេទន៍ស្តីពីការនាំចូលថ្នាំកសិកម្ម និងជីកសិកម្មរបស់ក្រុមហ៊ុនពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១៥ក្រុមហ៊ុន

- បានចុះធ្វើអធិការកិច្ចត្រួតពិនិត្យបទល្មើសថ្នាំកសិកម្ម និងជីកសិកម្មខេត្តគោលដៅចំនួន ២ខេត្ត គឺខេត្តសៀមរាប និងខេត្តឧត្តរមានជ័យលើដេប៉ូចំនួន ៦ដេប៉ូ សម្រេចពិន័យអន្តរការណ៍១ករណី។

**១៤ ផ្នែកមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម**

- បានថែទាំលើគេហទំព័រ (Web) និង Mobile App របស់ក្រសួង និងអង្គភាពក្រោមឱវាទក្រសួងសរុបចំនួន ១៧ (១៦គេហទំព័រ និង១កម្មវិធី) និងគេហទំព័រមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត

- បានតាមដានទិន្នន័យ និងសម្អាត Catch នៅលើ Cloud Server នៃគេហទំព័រទាំង៤១ (ក្រសួង អគ្គនាយកនាយកដ្ឋាន និងមន្ទីររាជធានី-ខេត្ត)

- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីសមិទ្ធផលប្រព័ន្ធព័ត៌មានវិទ្យាក្នុងវិស័យកសិកម្មរបស់មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្មមានអ្នកចូលរួមសរុប ១០៦នាក់។

## ១៥ ផ្នែកផ្សព្វផ្សាយកសិកម្ម វិទ្យុ ប្រមាញ់ និងនេសាទ

- បានចុះទៅថត Video បទយកការណ៍នៅខេត្តក្រចេះ និងខេត្តព្រៃវែងចំនួន ២ប្រធានបទ គឺ ការចិញ្ចឹមមាន់តាមបច្ចេកទេសថ្មី និងមុខរបរចិញ្ចឹមត្រីប្រា

- បានចាក់ផ្សាយឡើងវិញចំនួន ២ប្រធានបទ គឺ ការធ្វើកសិកម្មតាមកិច្ចសន្យា និងអត្ថប្រយោជន៍នៃការធ្វើកសិកម្មតាមកិច្ចសន្យា

- បានចុះផលិតនាទីចុះស្រែជាមួយកសិករចំនួន ២ប្រធានបទ គឺ បណ្តុំកសិករចិញ្ចឹមមាន់សាច់ និងបណ្តុំកសិករដាំដំណាំស្លឹកខ្ទឹម

- បានបញ្ជូនអត្ថបទបច្ចេកទេសកសិកម្មចំនួន ៦ដើម្បីចាក់ផ្សាយ គឺ ការរៀបចំភ្លឺរាស់ និងកៀរពង្រាបដីឱ្យបានស្មើសម្រាប់សាបព្រោះស្រូវរដូវវស្សា ពូជស្រូវរាំងជ័យ បច្ចេកទេសផលិតជីកំប៉ុស្ត និងថ្នាំកសិកម្មធម្មជាតិ បច្ចេកទេសដាំដំណាំម្ទេស បច្ចេកទេសចិញ្ចឹមមាន់លក្ខណៈគ្រួសារ និងបទពិសោធន៍ចិញ្ចឹមគោរបស់កសិករ

- បានចូលរួមសម្របសម្រួលរៀបចំកិច្ចប្រជុំបច្ចេកទេសកសិកម្មសម្រាប់គម្រោង LASED II ដែលមានអ្នកចូលរួមសរុបចំនួន ៣០នាក់ នៅខេត្តក្រចេះ។

## ១៦ ផ្នែកកសិ-ឧស្សាហកម្ម

- បានចូលរួមប្រជុំលើសេចក្តីព្រាងផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តសៀមរាបឆ្នាំ២០២០-២០៣៥
- បានចូលរួមប្រជុំពិនិត្យ និងពិភាក្សាបន្តលើសេចក្តីព្រាងច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ
- បានសម្របសម្រួលពិធីចុះកិច្ចសន្យាផលិតកម្មកសិកម្មតាមកិច្ចសន្យារវាងក្រុមហ៊ុន AMRU Rice និងសហគមន៍ចំនួន ២២នៅខេត្តកំពង់ធំ
- បានចុះពិនិត្យវឌ្ឍភាពការកសាងរោងចក្រកែច្នៃស្វាយចន្ទី ខ្សែចង្វាក់តម្លៃស្វាយចន្ទីនៅខេត្តកំពង់ធំ
- បានរៀបចំ និងពិនិត្យឡើងវិញនូវឧបករណ៍ និងសម្ភារសម្រាប់មន្ទីរពិសោធន៍
- បានវិភាគរកសមាសធាតុគីមី លោហៈធ្ងន់ គុណភាព និងអាហាររូបត្ថម្ភនៅក្នុងផលិតផលកសិកម្ម
- បានវិភាគរកសមាសធាតុ អាសូត ផូស្វ័រ និងប៉ូតាស្យូមនៅក្នុងជីលាមកសត្វ ជីកាកឡ ទឹកស្លោរគ្រាប់ស្វាយចន្ទី និងកាកសំណល់ផ្ទះបាយ
- បានវិភាគរកវត្តមានបាក់តេរីបង្កគ្រោះថ្នាក់ដូចជា *Salmonella spp, Escheria Coli/ E.coli, Enterobacteriaceae, Mold and Yeast, Total Plate Count and Aflatoxin (ppb)* នៅក្នុងបន្លែស្រស់ដាំលើទឹកដីដោយប្រើប្រាស់ទឹករដ្ឋសម្រាប់ផ្គត់ផ្គង់ខ្សែច្រវាក់នៃការដាដុះ
- បានស្រាវជ្រាវ និងផលិតដោយជោគជ័យលើការផ្សំរូបមន្តផលិតស្រ្តាយអាល់កុលប្រទាលកន្ទុយក្រពើសម្រាប់លាងសម្អាតដៃ។

## ១៧ ការស្រាវជ្រាវ ការអប់រំ និងការបណ្តុះបណ្តាលកសិកម្ម

### ១៧.១ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- បានចូលរួមវេទិកាពិគ្រោះយោបល់ស្តីពីដំណាំស្វាយថ្នាក់ខេត្តនៃគម្រោងខ្សែច្រវាក់ផលិតកម្មដោយភាគរៈបរិស្ថាន (CFAVC) នៅខេត្តកែប

- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការរៀបចំផែនការមេអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០៣០ នៅខេត្តកំពង់ចាម

- បានចុះធ្វើការវាយតម្លៃពីការសាយភាយ និងការទទួលយកបច្ចេកទេសប្រើប្រាស់ពូជ និងជីនៅខេត្តក្រចេះ

- បានចុះបើកវគ្គបណ្តុះបណ្តាលជូនកសិករចំនួន ១២០នាក់ និងត្រួតពិនិត្យការងារពិសោធន៍នៅខេត្តត្បូងឃ្មុំ និងខេត្តព្រៃវែង

- បានចុះជ្រើសរើសទីតាំងនិងរៀបចំពិសោធន៍នៅខេត្តតាកែវ

- បានចុះប្រមូលទិន្នន័យស្តីពីការរីកសាយ និងឥទ្ធិពលនៃការទទួលយកបច្ចេកវិទ្យាថ្មីនៅតំបន់ទំនាប និងខ្ពស់រាប នៅខេត្តត្បូងឃ្មុំ

- បានចូលរួមក្នុងទិវាស្រែបង្ហាញរបស់គម្រោងអំពីម៉ាស៊ីនដាំ និងការគ្រប់គ្រងស្មៅចង្រៃ នៅខេត្តបាត់ដំបង

- បានចុះដាំដុះដំណាំសណ្តែកដីសម្រាប់ការងារចម្ការពិសោធន៍បង្ហាញ នៅខេត្តកំពង់ស្ពឺ។

**១៧.២ សាកលវិទ្យាល័យភូមិន្ទកសិកម្ម**

- និស្សិតកំពុងសិក្សាក្នុងឆ្នាំសិក្សា២០១៩-២០២០ សរុបចំនួន ៣ ២៥៦នាក់ ចែកចេញជា១០ មហាវិទ្យាល័យ គឺ៖ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រជលផល កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងមហាវិទ្យាល័យវិទ្យា-សាស្ត្រកៅស៊ូ និងសាលាក្រោយឧត្តម

- បានចូលរួមជាវាគ្មិនពិសេសក្នុងវេទិកាស្តីពីតួនាទីរបស់អង្គការសង្គមស៊ីវិលក្នុងការទប់ស្កាត់ជំងឺកូវីដ-១៩ និងការលើកកម្ពស់សេដ្ឋកិច្ចគ្រួសារតាមរយៈការអនុវត្តនូវកសិកម្មសមស្របនៅខេត្តស្វាយរៀង ព្រៃវែង និងខេត្តត្បូងឃ្មុំ

- បានរៀបចំពិធីចែកកូនឈើ និងមាន់ពូជជូនប្រជាកសិករគោលដៅគម្រោង ស៊ូក្រា ក្នុងស្រុកតាលោសែនជ័យ ខេត្តពោធិ៍សាត់ និងស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង

- បានរៀបចំកិច្ចប្រជុំពិភាក្សាស្តីពីការរៀបចំកិច្ចសហការណ៍រវាងគម្រោងលើកកម្ពស់គុណភាពឧត្តមសិក្សា (HEIP) និងគម្រោងលើកកំពស់គុណភាពមធ្យមសិក្សា (SEIP) និងការកសាងគម្រោងថ្មី (GEIP) ជាមួយសាកលវិទ្យាល័យដៃគូទាំង៥ និងនាយកដ្ឋានអប់រំនៃក្រសួងអប់រំ យុវជន និងកីឡា

- បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីអំពីការរៀបចំគោលគំនិតដើម្បីបង្កើតសៀវភៅណែនាំ គ្រប់គ្រងបុគ្គលិក និងហិរញ្ញវត្ថុ

- បានបន្តការងារសិក្សាពិសោធន៍ស្រាវជ្រាវលើប្រធានបទដូចជា ការពិសោធន៍លើចំណីសត្វ ការចិញ្ចឹមសត្វ ការចាក់វ៉ាក់សាំង ពិសោធន៍លើអតិសុខុមប្រាណសាស្ត្រ បរាសិត ហើយនិស្សិតមួយចំនួនបានចុះហាត់ការងារផ្ទាល់នៅមន្ទីរពេទ្យសត្វនៃសាកលវិទ្យាល័យភូមិន្ទកសិកម្មដោយបានថែទាំសត្វសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងធ្វើជំនួយការក្នុងការវះកាត់ គ្រៀវសត្វ និងថត X-ray សត្វ។

**១៧.៣ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប**

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០១៩-២០២០ សរុបចំនួន ១ ០៨៨នាក់ (ស្រី៤៥៤នាក់) លើជំនាញ៖ កសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិស្វកម្មកសិកម្ម ព្រៃឈើ ជលផល សាកវប្បកម្ម សុរិយោដីនិងការគ្រប់គ្រងដី ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចកសិកម្ម មីក្រូហិរញ្ញវត្ថុ កែច្នៃអាហារ កុំព្យូទ័រ សេដ្ឋកិច្ចនយោបាយ និងស្បៀង និងភាសាអង់គ្លេស

- បានចុះអនុស្សរណៈនៃការយោគយល់គ្នា រវាងវិទ្យាស្ថានជាតិ និង លោក ហង្ស សុធី សម្រាប់ការអភិវឌ្ឍកសិកម្ម

- បានចុះទៅខេត្តព្រះវិហារដើម្បីសិក្សាអំពីលទ្ធភាពបង្កើតស្ថានីយស្រាវជ្រាវ

- បានចុះទៅខេត្តព្រះសីហនុដើម្បីសិក្សាពីលទ្ធភាពដីដែលអាចដាំស្វាយចន្ទី ព្រីង និងកែច្នៃឬស្សី

- បានទំនាក់ទំនងក្រុមហ៊ុនដាំចេកអំបូងលឿង ស្រេង ឡុង នៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាមដើម្បីបញ្ជូននិស្សិតដែលបញ្ចប់ការសិក្សាចំនួន ២០នាក់ (ស្រី៩នាក់) ទៅធ្វើការនៅក្រុមហ៊ុន

- បន្តការស្រាវជ្រាវលើ ផ្កាអ័រគីដេ ចេក ស្វាយចន្ទី និងត្រី

- បាននិងកំពុងដំណើរការសាងសង់កសិដ្ឋានចិញ្ចឹមគោយកទឹកដោះ។

**១៧.៤ វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម**

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០១៩-២០២០ សរុបចំនួន ៦៥៦នាក់ (ស្រី២៨៦នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម ក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- បានបញ្ជូននិស្សិតជំនាញវិទ្យាសាស្ត្រកសិកម្មឆ្នាំទី៤ ចំនួន៣នាក់ និងមន្ត្រីចំនួន១នាក់ ចូលរួមជាមួយគម្រោង ERECON លើការងារផ្សព្វផ្សាយបច្ចេកទេសកសិកម្មនិរន្តរភាព

- ពិសោធន៍លើជីសរីរាង្គពីការលូតលាស់ដំណាំបន្លែស្ពៃក្រញាញ់

- ពិសោធន៍តាមដានការបំផ្លាញរបស់កត្តាចង្រៃលើដំណាំខាត់ណាផ្កា

- ពិសោធន៍សាកល្បងផលិតមេជី Lacto Bacellus និងពិសោធន៍ឥទ្ធិពលមេជីលើការលូតលាស់ដំណាំស្ពៃក្តោប

និងស្រូវនៅស្រុកកំពង់សៀម ខេត្តកំពង់ចាម

- បាន់ធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហមនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្ម កំពង់ចាម

- បានធ្វើការពិសោធន៍លើការចិញ្ចឹមបង្កងពូជអូស្ត្រាលីចំនួន ១៦៥គូ និង២៥០កូន នៅស្ថានីយពិសោធន៍ជលផល នៃវិទ្យាស្ថានជាតិកសិកម្ម កំពង់ចាម

- បានចូលរួមបណ្តុះបណ្តាលកសិករជាមួយដៃគូរបស់ក្រុមហ៊ុន និងធ្វើការស្រាវជ្រាវរួមគ្នាអំពីការកែច្នៃកសិផល លើដំណាំស្វាយចន្ទី ល្ហុង ល្ពៅ ក្រូចថ្លុង ស្លឹកគ្រៃ និងម្រេច

- សហការជាមួយ DTRA (Defence Threat Reduction Agency) ក្នុងការបើកវគ្គបណ្តុះបណ្តាលចំនួន ៣វគ្គ ដូចជាជំងឺប៉ារ៉ាស៊ីតសត្វឆ្លងមកមនុស្សនៅកម្ពុជា អេពីដេមីសាស្ត្រនៃជំងឺផ្តាសាយបក្សី ជីវសុវត្ថិភាពសម្រាប់ជំងឺហ្សូណូស និងជំងឺសត្វឆ្លងដែនដល់និស្សិតជំនាញវិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រនៅវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម។

### ១៧.៥ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- បានស្រង់ទិន្នន័យជ័រកៅស៊ូឡូតិ៍ពិសោធន៍ក្លូន IRAA01-IRAA10, SSCT01 និង GSET02
- បានអង្កេតជំងឺលើគ្រប់ឡូតិ៍ពិសោធន៍ក្លូននៅក្នុងស្ថានីយ
- ត្រួតពិនិត្យការចៀរជ័រ និងការសាប្រមូលផលទឹកជ័រតាមពិធីពិសោធន៍គ្រប់ចម្ការពិសោធន៍
- ចុះស្រង់ទិន្នន័យជ័រកៅស៊ូនៅចម្ការពិសោធន៍សក្តានុពលទិន្នផលនៃប្រព័ន្ធ
- ត្រួតពិនិត្យការប្រមូលផលទឹកជ័រនៅចម្ការពិសោធន៍
- ថែទាំកូនកៅស៊ូស្ទុមក្នុងបំពង់ Root Trainer ក្លូន PMB1, GT1 និង IRCA230
- ដាំជួសកូនកៅស៊ូឆ្នាំ២០១៨-២០១៩ លើកទី២ នៅប្លុក42BNW និង 42BNE
- វាស់ទំហំដើមសម្រាប់បើកមុខចៀរថ្មី និងរៀបចំសម្ភារបំពាក់ដើម
- ថែទាំឡូតិ៍កៅស៊ូចៀរជ័រដូចជាលាបថ្នាំរំញោច និងលាបខ្លាញ់គោលើដើមកៅស៊ូចៀរជ័រ
- វិភាគលទ្ធផលតេស្តលើអាស៊ីតបីប្រភេទ (ស៊ុលផួរិក ហ្វ័រមិក និងម្សៅអាស៊ីត) របស់និស្សិតសរសេរសារណាបទបញ្ចប់ការសិក្សានៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម។

## III-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាធ្វើការដាំដុះបានចំនួន ២ ៥៤៧ ៤២០ហ.ត ស្មើនឹង៩៨,៤៣% នៃផែនការចំនួន ២ ៥៨៨ ១៣០ហ.ត។ ក្រសួងក៏បានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើយន្តការ និងបទដ្ឋានបច្ចេកទេសគន្លឹះសំខាន់ៗ តាមការចាំបាច់ និងសហការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការតាមដានវាយតម្លៃអំពីការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសត្វល្អិតចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ដូចជាការជំរុញឱ្យចុះត្រួតពិនិត្យ និងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វឈឺក្នុងតំបន់ផ្ទុះជំងឺ បទល្មើសព្រៃឈើ និងជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រង ការត្រួតពិនិត្យអនាម័យ នឹងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងក៏បានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រ គោលនយោបាយតាមអនុវិស័យសំខាន់ៗឱ្យសម្រេចបាននូវលទ្ធផលល្អប្រសើរតាមផ្នែកនីមួយៗស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម។

ជារួម ដោយមានការជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងពីរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា គួបផ្សំនឹងការខិតខំឧស្សាហ៍ព្យាយាម និងការផ្លាស់ប្តូរទម្លាប់របស់ប្រជាកសិករផង បានជំរុញឱ្យដំណើរការផលិតកម្មកសិកម្មទទួលបានជោគជ័យ និងជម្នះដោះស្រាយនូវរាល់ការលំបាកផ្សេងៗប្រកបដោយមោទនភាព ពិតមែនតែនៅមានបញ្ហាប្រឈមខ្លះៗក៏ដោយ។

## IV- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ

- បន្តវិធានការជំរុញការងារបង្កបង្កើនផលកសិកម្មនៅក្នុងរដូវវស្សាឆ្នាំ២០២០
- បន្តធ្វើការពិនិត្យសន្និធិស្បៀងសម្រាប់ឆ្លើយតបទៅនឹងហានិភ័យនៃការឆ្លងរាលដាលជំងឺកូវីដ-១៩
- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណ និងគុណភាពតាមផែនការកំណត់ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង
- បន្តជំរុញ និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស និងកសិករអំពីបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និងបន្តការសិក្សាស្រាវជ្រាវបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ការងារផលិតពូជ និងបន្សុទ្ធពូជនៅកសិដ្ឋាន និងស្ថានីយ
- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់នឹងជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្មសម្រាប់ការងារបង្កបង្កើនផល
- បន្តអង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ។

### ២ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗទៀត ព្រមទាំងចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទរួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង
- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន
- ចុះពិនិត្យអនាម័យសត្តឃាតដ្ឋាន ផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកគ្រុនចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត
- បន្តការតាមដានស្ថានភាពជំងឺស៊ូណូសជាប្រចាំនៅតាមបណ្តារាជធានី-ខេត្ត
- ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យ កន្លែងផ្ទុះជំងឺ និងកន្លែងដែលរាលដាលជំងឺផ្តាសាយបក្សី (H5N1) និងជំងឺ A(H1N1)
- បន្តអនុវត្តការបង្កាត់ពូជគោ និងជ្រូកដោយសិប្បនិម្មិត។

### ៣ ផ្នែកព្រៃឈើ

- ខិតខំបន្តត្រួតពិនិត្យ តាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រ សិប្បកម្មកែច្នៃ និងអាជីវកម្មឈើឲ្យបានហ្មត់ចត់ ព្រមទាំងចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាតដើម្បីលុបបំបាត់សកម្មភាពដឹកជញ្ជូនឈើខុសច្បាប់ឲ្យមានប្រសិទ្ធភាពខ្ពស់
- បន្តពង្រឹង និងពង្រីកសហគមន៍ព្រៃឈើឲ្យចូលរួមគ្រប់គ្រងថែរក្សាធនធានព្រៃឈើ តាមដានត្រួតពិនិត្យ ការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ឲ្យបានល្អ ព្រមទាំងបណ្តុះផ្នត់គំនិតបង្កើតមុខរបរថ្មីៗបន្ថែមទៀត ដើម្បីបង្កើនចំណូលតាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម ការចិញ្ចឹមសត្វ សំដៅកាត់បន្ថយការពឹងអាស្រ័យលើផល និងអនុផលព្រៃឈើ ជាពិសេសខិតខំជំរុញការផ្សព្វផ្សាយ អប់រំ បណ្តុះបណ្តាល បំពាក់បំប៉នដល់សហគមន៍មូលដ្ឋាន ឲ្យយល់ដឹងពីផលប្រយោជន៍ព្រៃឈើ
- បន្តផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទប្បញ្ញត្តិ បទបញ្ជា លិខិតបទដ្ឋានគតិយុត្ត ជាពិសេសសេចក្តីជូនដំណឹងលេខ១៣៤៨ សជណ.កជ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីឲ្យបានជ្រួតជ្រាបដល់មូលដ្ឋានភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង រាជធានី-ខេត្តទូទាំងប្រទេស ព្រមទាំងមានចំណាត់ការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ និងឲ្យមានប្រសិទ្ធភាពខ្ពស់ពាក់ព័ន្ធនឹងការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីវាតយកដីធ្វើកម្មសិទ្ធិ
- បន្តជំរុញការដាំដុះស្តារព្រៃឈើឡើងវិញដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសម្រាប់ចែកចាយជូនប្រជាពលរដ្ឋ។

**៤ ផ្នែកជលផល**

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីជលផលឱ្យបានតឹងរ៉ឹងបំផុត

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"។

**៥ ផ្នែកពាក់ព័ន្ធផ្សេងៗ**

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់ជី-ថ្នាំកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់ជី-ថ្នាំកសិកម្ម ដើម្បីសុខភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្តែង រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា អភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាឱ្យមានផលិតភាពខ្ពស់ដោយគិតគូរទៅលើការប្រែប្រួលអាកាសធាតុ និងស្តង់ដារ។

ថ្ងៃព្រហស្បតិ៍ ១រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**